# vFbsa®sþresrGtbSTRsavRCav

ហេង ស្រ៊ាង

Research methodology
HENG Sreang

នៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅនៅប្រទេសកម្ពុជា វិធីសាស្ត្រសរសេរតែងសេចក្តីត្រូវបានគេបង្រៀនដល់សិស្សានុសិស្សចាប់តាំងពីបឋមសិក្សារហូតដល់វិទ្យាល័យ។ ប៉ុន្តែមុខវិជ្ជាវិធីសាស្ត្រសរសេរអត្ថបទស្រាវជ្រាវពុំមានឡើយ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានដេប៉ាតឺម៉ង់មួយចំនួន បានដាក់បញ្ចូលមុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវក្នុងកម្មវិធីសិក្សារបស់ខ្លួន ដូចជាដេប៉ាតឺម៉ង់សង្គមសាស្ត្រនៅឆ្នាំ១៩៩៤ ដេប៉ាតឺម៉ង់ប្រវត្តិសាស្ត្រនៅឆ្នាំ១៩៩៦ ដេប៉ាតឺម៉ង់អក្សរសាស្ត្រ ចិត្តវិទ្យា ភូមិវិទ្យា ទស្សនវិជ្ជានៅឆ្នាំ១៩៩៩-២០០០។ ប៉ុន្តែនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញនេះដែរ មានដេប៉ាតឺម៉ង់មួយចំនួនធំពុំមានមុខវិជ្ជានេះនៅក្នុងកម្មវិធីសិក្សារបស់ខ្លួនទេ ហើយក៏ដូចជានៅសាកលវិទ្យាល័យ មហាវិទ្យាល័យ និងវិទ្យាស្ថានឯកជនមួយចំនួនធំទៀតដែរ។ ដូច្នេះ និស្សិតដែលបានបញ្ចប់ការសិក្សាមុនឆ្នាំខាងលើនេះ ពុំមានឱកាសស្វែងយល់ពីមុខវិជ្ជាវិធីសាស្ត្រស្រាវជ្រាវនេះឡើយ។

ដោយមើលឃើញអំពីកង្វះខាតនូវចំណេះដឹងខាងផ្នែកសរសេរអត្ថបទស្រាវជ្រាវនេះ ខ្ញុំបាទ និងលោក John Weeks បានសហការគ្នាធ្វើកិច្ចការស្តីអំពីវិធីសាស្ត្រសរសេរអត្ថបទស្រាវជ្រាវនេះ ដើម្បីចែករំលែកនូវពុទ្ធិស្តីអំពីវិធីសាស្ត្រខាងលើដែលពួកយើងខ្ញុំបានចេះចាំខ្លះ ថ្វាយជូនដល់ព្រះសង្ឃ អស់លោក លោកស្រី និស្សិត បញ្ញវន្ត សិស្សានុសិស្ស និងប្អូនៗទាំងឡាយ។ អត្ថបទនេះនឹងនិយាយអំពី «ថាតើត្រូវសរសេរអត្ថបទស្រាវជ្រាវយ៉ាងដូចម្តេចដើម្បីឱ្យត្រូវតាមវិធីសាស្ត្រ និងមានលក្ខណៈវិទ្យាសាស្ត្រ»។

## *តើត្រូវសរសេរអត្ថបទស្រាវជ្រាវយ៉ាងដូចម្តេច?*

មានមនុស្សជាច្រើនដែលតែងតែនិយាយថាខ្លួនមិនដឹងសរសេរអំពីអ្វីឡើយ។ នេះជាការតូញត្អែរមួយ ដែលប្រកបដោយការចង់ចេះចង់ដឹង ហើយការតូញត្អែរនេះឯង មិនមែនមានតែចំពោះអ្នកដែលស្ថិតនៅក្នុងប្រទេសដែលមានការអប់រំនៅទន់ខ្សោយឡើយ។ ប៉ុន្តែវាក៏ជាការតូញត្អែរដែលតែងកើតមានឡើងចំពោះអ្នកដែលរស់នៅក្នុងប្រទេសដែលមានការអប់រំខ្ពស់ដែរ។ ប៉ុន្តែអ្នកដែលតូញត្អែរ

អំពីកិច្ចការនេះ ពិតជាភ្លេចថាខ្លួនបានចំណាយពេលជាច្រើនម៉ោងក្នុងមួយថ្ងៃ ក្នុងមួយសប្តាហ៍ ក្នុងមួយខែ ក្នុងមួយឆ្នាំៗ ក្នុងការនិយាយ បរិយាយពីរឿងផ្សេងៗ។ តែតាមពិត អ្វីដែលខ្លួននិយាយ បរិយាយនេះឯង វាអាចជាប្រយោជន៍ដល់ការសរសេរកិច្ចការរបស់ខ្លួន គឺពីបាល់ទាត់ទៅសេរីភាព ខាងផ្នែកបញ្ញា របាំបុរាណខ្មែរ រឿងនិទានខ្មែរ ព្រះពុទ្ធ ខុងជឺ សូក្រាត ប្លាតុង អារីស្តូត។ល។

## អ្វីទៅដែលហៅថាអត្ថបទស្រាវជ្រាវ?

អត្ថបទស្រាវជ្រាវ គឺជាអត្ថបទដែលសរសេរបង្ហាញនូវគំនិត រឺទស្សនៈណាមួយប្រកបដោយការពិភាក្សា ប្រៀបធៀប ពន្យល់ និងសន្និដ្ឋានដែលមានលក្ខណៈរៀបចំត្រឹមត្រូវ ដោយធ្វើការសិក្សាពិនិត្យសង្កេតទៅលើស្នាដៃរបស់អ្នកដទៃ។

ក្នុងនាមជាអ្នកស្រាវជ្រាវ យើងត្រូវចាប់ផ្តើមសួរខ្លួនយើងថា «តើយើងមានបំណងចង់ស្វែងយល់អំពីអ្វី? តើយើងត្រូវស្វែងរកអ្វី? តើយើងសង្ឃឹមថានឹងសំរេចបានអ្វីពីការសិក្សាស្រាវជ្រាវរបស់យើង? កិច្ចការរបស់យើងត្រង់ចំនុចនេះ គឺត្រូវស្វែងរកនូវចំលើយចំពោះសំណួរទាំងនេះ។ ពេលខ្លះយើងអាចគិតថា យើងបានដឹងនូវចំលើយខ្លះជាមុន។ ប៉ុន្តែត្រូវចាំថាគោលការណ៍បឋមនៃអត្ថបទស្រាវជ្រាវ គឺភាពបរានុម័ត ពោលគឺអ្នកស្រាវជ្រាវមិនត្រូវមានគំនិតបុរេនិច្ឆ័យចំពោះកិច្ចការស្រាវជ្រាវរបស់ខ្លួនឡើយ។ អ្នកស្រាវជ្រាវត្រូវពឹងផ្អែកលើការសង្កេតពិនិត្យឱ្យបានច្បាស់លាស់នូវការណ៍ រឺទិន្នន័យទាំងឡាយដែលខ្លួនប្រមូលបាន ប្រកបដោយគតិបញ្ញា និងភាពស្មោះត្រង់ជាមុនសិន។ បន្ទាប់មកទៀត ត្រូវធ្វើការថ្លឹងថ្លែងប្រៀបធៀបលើទិន្នន័យ ដើម្បីអោយបានប្រាកដថា ការសន្និដ្ឋានរបស់យើងត្រឹមត្រូវដែរឬយ៉ាងណា។ ការសន្និដ្ឋានដែលត្រឹមត្រូវ គឺការសន្និដ្ឋានទាំងឡាយណាដែលបានធ្វើឡើងប្រកបដោយការគិតពិចារណា និងប្រកបដោយពុទ្ធិពិតប្រាកដ។

ការអនុវត្តន៍វិធីស្រាវជ្រាវដែលមានការរៀបចំប្លង់ផែនការត្រឹមត្រូវ បានក្លាយទៅជាកិច្ចការដែលមានលក្ខណៈទូទៅហើយនៅពេលបច្ចុប្បន្ននេះ។ វិទ្យាស្ថានធំៗទាំងឡាយនៅក្នុងប្រទេសរីកចំរើនគេរក្សាទុកនៅតែបុគ្គលិកទាំងឡាយណាដែលចូលចិត្តធ្វើការស្រាវជ្រាវ។ នៅក្នុងសាកលវិទ្យាល័យមហាវិទ្យាល័យ និងវិទ្យាស្ថានធំៗមួយចំនួន តំរូវឱ្យនិស្សិតទាំងឡាយសរសេរអត្ថបទស្រាវជ្រាវដើម្បីបញ្ចប់កិច្ចការក្នុងមុខវិជ្ជាដែលខ្លួនសិក្សា ដោយមិនចាំបាច់ប្រលងសរសេរឡើយ។ គេចាត់ទុកថាអត្ថបទស្រាវជ្រាវដែលនិស្សិតទាំងឡាយត្រូវធ្វើ ជារង្វាស់នូវចំណេះដឹងពិតដែលនិស្សិតមាន។

ចំពោះអ្នកស្រាវជ្រាវ បណ្ណាល័យមានសារសំខាន់ណាស់។ ភាពឥតខ្ចោះនៃសំណេរកិច្ចការស្រាវជ្រាវមួយផ្នែកធំត្រូវពឹងផ្អែកទៅលើការយកចិត្តទុកដាក់របស់អ្នកស្រាវជ្រាវ លើកិច្ចការ

ស្រាវជ្រាវក្នុងបណ្ណាល័យជាច្រើនដំណាក់កាល។ នៅខាងក្រោមនេះ ខ្ញុំបាទលើកយកដំណាក់កាលសំខាន់ៗប្រាំ ដែលតែងត្រូវបានគេប្រើជាទូទៅក្នុងការរៀបចំនិងសរសេរអត្ថបទស្រាវជ្រាវ ÷

**ដំណាក់កាលទី១ : ការជ្រើសរើសប្រធានបទ**

អត្ថបទស្រាវជ្រាវ មិនមែនជាអត្ថបទដែលកើតចេញពីកិច្ចការដែលធ្វើដោយបង្ខិតបង្ខំចិត្តឡើយ។ ប៉ុន្តែវាជាកិច្ចការដែលកើតរឺផ្តើមចេញពីចំណង់ចំណូលចិត្ត ចំណង់បាននូវពុទ្ធិ រឺអ្វីដែលអ្នកស្រាវជ្រាវប្រាថ្នាចង់ចេះចង់ដឹង ហើយចង់ទទួលយកកិច្ចការស្រាវជ្រាវនេះមកធ្វើដោយទំនួលខុសត្រូវផ្ទាល់ខ្លួន ដោយធ្វើការសិក្សាស្រាវជ្រាវរាវរកព័ត៌មានទិន្នន័យផ្សេងៗ ដើម្បីសរសេរបកស្រាយក្នុងអត្ថបទរបស់ខ្លួន។ ពោលគឺការជ្រើសរើសយកប្រធានបទណាមួយមកសរសេរ ត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃចំណង់ចំណូលចិត្ត និងការយល់ឃើញពីតំលៃនៃការស្រាវជ្រាវនោះជាមូលដ្ឋាន។ ប្រសិនបើកិច្ចការស្រាវជ្រាវនេះផ្តើមចេញពីចំណង់ចំណូលចិត្តរបស់អ្នកស្រាវជ្រាវផ្ទាល់ នោះវានឹងធ្វើអោយអ្នកស្រាវជ្រាវនោះឯងពេញចិត្តនឹងចំណាយពេលវេលាខិតខំធ្វើការស្រាវជ្រាវដែលអាចធានាបានថា កិច្ចការរបស់ខ្លួននឹងចប់សព្វគ្រប់។ តែបើការជ្រើសរើសប្រធានបទនោះមិនបានផ្តើមចេញពីចំណង់ចំណូលចិត្តផ្ទាល់របស់អ្នកសរសេរទេនោះ ពេលនោះពិតជាធ្វើឱ្យការស្រាវជ្រាវនិងការសរសេររបស់អ្នកនោះមិនបានល្អឡើយ ហើយជួនកាលអ្នកនោះមិនអាចនឹងសរសេរកិច្ចការរបស់ខ្លួនបានចប់សព្វគ្រប់ផងក៏មាន។

បន្ទាប់ពីបានជ្រើសរើសប្រធានបទហើយ អ្នកសរសេរត្រូវធ្វើការពិនិត្យពិច័យអោយបានហ្មត់ចត់ថាតើប្រធានបទនោះមានលក្ខណៈចង្អៀតពេក រឺក៏ទូលំទូលាយពេក។ ប្រសិនបើវាមានលក្ខណៈចង្អៀតពេក អ្នកសរសេរត្រូវពង្រីកវាបន្ថែម តែបើវាធំ រឺទូលំទូលាយពេក អ្នកសរសេរត្រូវបង្រួមវាមកវិញ។ ឧទាហរណ៍ : ប្រធានបទស្តីពី

-«ទេសចរណ៍» (ជាប្រធានបទ ដែលមានលក្ខណៈទូលំទូលាយពេក)

↓

-ទេសចរណ៍នៅប្រទេសកម្ពុជា (ប្រធានបទមានលក្ខណៈធំល្មម)

↓

-ទេសចរណ៍នៅក្រុងសៀមរាប (ប្រធានបទមានលក្ខណៈតូចល្មម)

ការបង្រួម រឺការកំណត់ទំហំនៃប្រធានបទ នឹងធ្វើអោយអ្នកស្រាវជ្រាវផ្តោតការអានរបស់ខ្លួនបាន ចំគោលដៅ ហើយធ្វើប្លង់សំណេររបស់ខ្លួនបានសុក្រឹតល្អតាមគោលបំណងដែលខ្លួនចង់បាន។

**ដំណាក់កាលទី២ ៖ ការប្រមូលឯកសារពិគ្រោះ**

បន្ទាប់ពីយើងសំរេចយកប្រធានបទណាមួយហើយនោះ យើងត្រូវរុករក រឺប្រមែប្រមូលឯកសារនានា ដែលយើងនឹងប្រើជាឯកសារពិគ្រោះក្នុងសំណេររបស់យើង មានដូចជាសៀវភៅ ទស្សនាវដ្ដី ព្រឹត្តិបត្រ សារព័ត៌មាននានា។ល។ យើងត្រូវប្រាកដថា យើងប្រមូលឯកសារដែលត្រូវ (ដែលចំ) និងពាក់ព័ន្ធទៅនឹងប្រធានបទដែលយើងបានជ្រើសរើសហើយ។ ចូរប្រាកដថាឯកសារដែលយើងប្រមូលបាននោះ គ្រប់គ្រាន់សំរាប់សំណេររបស់យើង។ ឯកសារពិគ្រោះមានសារសំខាន់ណាស់សំរាប់អត្ថបទស្រាវជ្រាវ ពីព្រោះឯកសារពិគ្រោះនឹងធ្វើអោយអ្នកអានមានជំនឿទុកចិត្តលើអ្នកសរសេរ។ ឯកសារពិគ្រោះមានពីរប្រភេទ គឺឯកសារដើម និងឯកសារពិគ្រោះទីពីរ (ឯកសារបន្ទាប់បន្សំ)។ ឯកសារដើម ជាឯកសារដែលកើតចេញពីគំនិតផ្ទាល់របស់អ្នកប្រាជ្ញ រឺអ្នកនិពន្ធ ដែលបាននិយាយអំពីការណ៍ រឺព្រឹត្តិការណ៍ផ្ទាល់។ ឯកសារទីពីរ (រឺឯកសារបន្ទាប់បន្សំ) ជាឯកសារដែលបានសរសេរឡើងដើម្បីនិយាយ បកស្រាយ ពិគ្រោះលើឯកសារដើមនោះ។

**ដំណាក់កាលទី៣ ៖ ការដកស្រង់យកខ្លឹមសារសំខាន់ពីការអាន**

បន្ទាប់ពីប្រមូលឯកសារពិគ្រោះបានសព្វគ្រប់ហើយនោះ យើងត្រូវអានឯកសារទាំងនោះហើយដកស្រង់យកគំនិត ខ្លឹមសារសំខាន់ៗទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រធានបទរបស់យើង។ យើងត្រូវចាំថាសុក្រឹតភាពនៃអត្ថបទស្រាវជ្រាវរបស់យើងមួយភាគធំ ត្រូវផ្អែកលើសុក្រឹតភាពនៃការដកស្រង់យកខ្លឹមសារសំខាន់ពីឯកសារដែលយើងបានអាន។ ដូច្នេះពេលយើងអាន យើងមិនត្រូវដកស្រង់ឬចំលងយកអ្វីដែលមិនពាក់ព័ន្ធទៅនឹងខ្លឹមសារស្នូលនៃសំណេររបស់យើងឡើយ ពីព្រោះវាធ្វើឱ្យយើងខាតពេលវេលានិងអាចធ្វើឱ្យយើងច្រឡំនៅពេលដែលយើងសរសេរ។

វិធីដកស្រង់យកនូវខ្លឹមសារសំខាន់ពីឯកសារដែលយើងបានអាន យើងត្រូវប្រើក្រដាសសៀវភៅដាច់ដោយឡែកពីគ្នាមួយៗ ដើម្បីសរសេរខ្លឹមសារដែលយើងបានដកស្រង់ពីការអានរបស់យើង។ នៅពេលសរសេរសម្រង់ខ្លឹមសារលើក្រដាសនីមួយៗនោះ យើងត្រូវសរសេរជាបឋមគឺឈ្មោះអ្នកនិពន្ធ ចំណងជើងសៀវភៅ ទីកន្លែងបោះពុម្ព ឈ្មោះរោងពុម្ព កាលបរិច្ឆេទនៃការ

បោះពុម្ព និងលេខទំព័រ។ ថែមពីលើនេះយើងក៏ត្រូវកត់សំគាល់ផងដែរអំពីសម្រង់ខ្លឹមសារផ្ទាល់ (direct quotation) ដែលជាសម្រង់ខ្លឹមសារពីឯកសារដើម និងសម្រង់ខ្លឹមសារមិនផ្ទាល់ (indirect quotation) ដែលជាសម្រង់ខ្លឹមសារពីឯកសារទីពីរ (ឯកសារបន្ទាប់បន្សំ) ដែលជាឯកសារបកស្រាយ ពិភាក្សាទៅលើឯកសារដើម។

**ដំណាក់កាលទី៤ ៖ ការធ្វើគំរោង ប្លង់ ឬមាតិកា**

នេះជាដំណាក់កាលដែលយើងត្រូវដាក់បញ្ចូលគ្នានូវសម្រង់ខ្លឹមសារឬទិន្នន័យទាំងឡាយ ដែលយើងប្រមូលបាន ឱ្យទៅជាគំរោង ឬប្លង់ ឬអាចហៅថាជាមាតិកាមួយ។ ដូចយើងបានដឹងស្រាប់ហើយថា ប្លង់ ឬមាតិការបស់សំណេរ ត្រូវចាប់ផ្ដើមពីលំនាំដើម (លំនាំសេចក្ដី) បន្ទាប់មកតួសេចក្ដីហើយចុងក្រោយសេចក្ដីសន្និដ្ឋាន។ ដូច្នេះយើងត្រូវគិតថាតើយើងត្រូវដាក់អត្ថន័យមួយត្រង់ណាហើយអត្ថន័យមួយទៀតត្រង់ណា ដើម្បីឱ្យសំណេររបស់យើងមានន័យច្បាស់លាស់។ ត្រង់ចំណុចនេះ យើងគួរកត់សំគាល់ថារបៀបដែលយើងរៀបចំ របៀបដែលយើងដាក់បញ្ចូលគ្នានូវសម្រង់ខ្លឹមសារ ឬទិន្នន័យដែលយើងប្រមូលបាន ធ្វើយ៉ាងណាឱ្យត្រឹមត្រូវតាមលំដាប់លំដោយស៊ីសង្វាក់ប្រទាក់ក្រឡាគ្នាជាផ្លូងមួយ ហើយមានអត្ថន័យច្បាស់លួនិងឆ្លុះបញ្ចាំងពីចំណុចស្នូល (Thesis) ពោលគឺចំណុចសំខាន់នៃសំណេររបស់យើង។

**ដំណាក់កាលទី ៥ ៖ ការសរសេរ**

នៅពេលដែលយើងរកឯកសារពិគ្រោះបានគ្រប់គ្រាន់ហើយ បានអាន និងដកស្រង់ខ្លឹមសារសំខាន់ៗហើយរៀបចំសម្រង់ខ្លឹមសារទាំងឡាយនោះឱ្យមានប្លង់ ឬមាតិកា និងបានធ្វើការពិនិត្យវាយតម្លៃលើប្លង់នេះរួចហើយ នោះយើងអាចចាប់ផ្ដើមសរសេរបានហើយ។

នៅពេលចាប់ផ្ដើមសរសេរ យើងត្រូវចាប់ផ្ដើមការអះអាងរបស់យើង ដោយផ្អែកលើសម្រង់ខ្លឹមសារ ឬទិន្នន័យដែលយើងប្រមូលបាន។ ទិន្នន័យទាំងនេះជាភស្តុតាងដែលយើងត្រូវពឹងផ្អែកលើវាជាចាំបាច់។ តែត្រូវចាំថា ទោះជាអត្ថបទស្រាវជ្រាវមួយភាគធំត្រូវពឹងផ្អែកទៅលើសម្រង់ខ្លឹមសារ ឬទិន្នន័យដែលយើងប្រមូលបានពីឯកសារផ្សេងៗក៏ដោយ ក៏វាមិនមែនជាអត្ថបទដែលកើតចេញពីការដែលគ្រាន់តែរៀបចំដាក់បញ្ចូលគ្នា ឬគ្រាន់តែជាការតភ្ជាប់គ្នានូវទិន្នន័យទាំងនោះឱ្យទៅជាអត្ថបទមួយដែលមានភាពរួមប្រទាក់ក្រឡាគ្នាប៉ុណ្ណោះទេ។ ប៉ុន្តែវាត្រូវតែជាអត្ថបទដែលសរសេរ

ឡើងប្រកបដោយការច្នៃប្រឌិតខ្ពស់ ដែលក្នុងនោះតម្រូវឱ្យអ្នកនិពន្ធ ឬអ្នកសរសេរចេះប្រើបញ្ញាញាណ និងចំណេះដឹងពិតដែលខ្លួនមាន ដើម្បីពន្យល់ បកស្រាយ ពិភាក្សា ប្រៀបធៀបទស្សនៈនានាប្រកបដោយតក្កភាព (logic)។ ធ្វើដូចនេះទើបនៅចុងបញ្ចប់ យើងអាចធ្វើសេចក្ដីសន្និដ្ឋានមួយប្រកបដោយប្រត្យក្សភាព និងសុក្រឹតភាព។

ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចទៀតថា នៅក្នុងដំណាក់កាលដែលយើងសរសេរនេះ យើងត្រូវសរសេរព្រាងជាមុនសិន។ យើងអាចសរសេរព្រាងលើកទីមួយ លើកទីពីរ ឬលើកទីបី ហើយបន្ទាប់ពីបានអានសេចក្ដីព្រាងនោះហើយ យើងយល់ថាសំណេររបស់យើងមានភាពពេញលេញហើយនោះ យើងអាចចាត់ទុកថាកិច្ចការសរសេររបស់យើងដល់ទីបញ្ចប់ហើយ។ តែកិច្ចការចុងក្រោយមួយទៀត គឺត្រូវពិនិត្យសង្កេតមើល អក្ខរាវិរុទ្ធ ឯកសារយោង រឺឯកសារពិគ្រោះជាមុនសិន មុនពេលប្រគល់កិច្ចការនេះទៅឱ្យគេ (ដូចជាគ្រូ ឬគណៈកម្មការពានរង្វាន់ ជាដើម)៕